# AGES & STAGES QUESTIONNAIRES®

## Ages & Stages Questionnaire - 3 (ASQ-3)®

### តើអ្វីជា ASQ -3?

ASQ-3 គឺជាបញ្ជីសំណួរ ស្តីអំពីការលូតលាស់របស់កូនអ្នក និងផ្តល់ការពិនិត្យមើលរហ័សអំពីស្ថានភាពរីកចម្រើនរបស់កូនអ្នក ក្នុងវិស័យសំខាន់ៗ ដូចជាការទំនាក់ទំនង សមត្ថភាពរាងកាយ ជំនាញសង្គម និងជំនាញដោះស្រាយបញ្ហា ។

### នរណាជាអ្នកបំពេញសំណួរ ASQ-3?

បញ្ជីសំណួរ ASQ-3 ត្រូវបំពេញដោយអ្នកមើលថែកូនអ្នក ។ គឺត្រូវចំណាយពេលប្រហែល 10-15 នាទី ។ វាលឿន ហើយងាយស្រួល ។

### នេះជាដំណើរការនៃបញ្ជីសំណួរ ASQ-3 ៖

ត្រូវឆ្លើយសំណួរនីមួយៗថា "បាទ/ចាស" "ជួនកាល" ឬ "នៅឡើយ" យោងតាមអ្វីដែលកូនអ្នកអាចធ្វើបាននៅពេលនេះ ។ ចម្លើយរបស់អ្នកអាចបង្ហាញបាននូវភាពខ្លាំងរបស់កូនអ្នក ព្រមទាំងវិស័យដែលកូនអ្នកអាចត្រូវខិតខំអនុវត្ត ។

ដើម្បីឆ្លើយសំណួរនីមួយៗ អ្នកអាចរៀបចំធ្វើសកម្មភាពរីករាយ និងងាយៗជាមួយកូនអ្នក ។ សកម្មភាពទាំងអស់នេះ ជួយលើកទឹកចិត្តឲ្យកូនអ្នកលេង រត់ចុះឡើង និងអនុវត្តជំនាញត្រូវប្រើប្រចាំថ្ងៃផងដែរ ។

ក្រោយពេលអ្នកបំពេញបញ្ជីសំណួរចប់ហើយ អ្នកត្រូវយកលទ្ធផលនេះ ទៅពិភាក្សាជាមួយនឹងអ្នកឯកទេសរបស់កូនអ្នក ។ ជាមួយអ្នកឯកទេស គឺអ្នកត្រូវកំណត់ជំហានបន្ទាប់ និងអ្វីជាគោលដៅ ដែលត្រូវសម្រេចនៅពេលខាងមុខ ។

## Ages & Stages Questionnaire: Social-Emotional - 2 (ASQ:SE - 2)®

### តើអ្វីជា ASQ ៖ SE - 2?

ASQ:SE-2 គឺជាបញ្ជីសំណួរ សម្រាប់ជួយក្នុងការរកមើលភាពខ្លាំងចិត្តសង្គមរបស់កូនអ្នក ព្រមទាំងរកមើលវិស័យដែលកូនអ្នកត្រូវការការជ្រោមជ្រែង ។ ការអភិវឌ្ឍន៍ចិត្តសង្គមរបស់កុមារ ផ្តោតលើ របៀបដែលកុមារចាប់ផ្តើមយល់ថាតើខ្លួនជានរណា, តើខ្លួនមានអារម្មណ៍បែបណា និងអ្វីដែលត្រូវរំពឹងនៅពេលទំនាក់ទំនងជាមួយអ្នកដទៃ ។

### នរណាជាអ្នកបំពេញសំណួរ ASQ:SE-2?

បញ្ជីសំណួរ ASQ:SE-2 ត្រូវបំពេញដោយអ្នកមើលថែកូនអ្នក ។ គឺត្រូវចំណាយពេលប្រហែល 10-15 នាទី ។ វាលឿន ហើយងាយស្រួល ។

### នេះជាដំណើរការនៃបញ្ជីសំណួរ ASQ:SE-2 ៖

សូមឆ្លើយសំណួរនីមួយៗ ដោយគូសលើពាក្យ "ញឹកញាប់ ឬជានិច្ចកាល" "ជួនកាល" ឬ "កម្រ ឬមិនដែល" ។ ត្រូវឆ្លើយតាមអ្វីដែលអ្នកដឹងអំពីកូនអ្នក ។

សូមបញ្ចេញយោបល់ បើសិនជាអ្នកមានការព្រួយបារម្ភអំពីអាកប្បកិរិយាណាមួយរបស់កូនអ្នក ។

សូមចងចាំថា ចម្លើយរបស់អ្នក ជួយបង្ហាញពីចំណុចខ្លាំងរបស់កូនអ្នក និងអាចរកឃើញនូវវិស័យដែលកូនអ្នកត្រូវការការជ្រោមជ្រែង ។

ក្រោយពេលអ្នកបំពេញបញ្ជីសំណួរចប់ហើយ អ្នកត្រូវយកលទ្ធផលនេះ ទៅពិភាក្សាជាមួយនឹងអ្នកឯកទេសរបស់កូនអ្នក ។ ជាមួយអ្នកឯកទេស គឺអ្នកត្រូវកំណត់ជំហានបន្ទាប់ និងអ្វីជាគោលដៅ ដែលត្រូវសម្រេចនៅពេលខាងមខ ។

ស្កែនដើម្បី

Ages & Stages Questionnaires® និង ASQ® គឺជាសញ្ញាពាណិជ្ជកម្មដែលបានចុះបញ្ជីរបស់ ASQ©, ASQ©-3, ហើយ ASQ©:SE-2 ជាកម្មសិទ្ធិរបស់ Paul H. Brookes Publishing Co., Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។